01100198

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 26 / 05 / 2015
ម៉ោង (Time/Heure): 12:20
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Sann Rada

002/19-09-2007-ECCC/TC
E1/300

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

## កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

## សាធារណៈ

### សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសង

### ថ្ងៃ ចន្ទ ទី ១៨ ខែ ឧសភា ឆ្នាំ ២០១៥

### សវនាការលើអង្គសេចក្តី - ថ្ងៃ ២៨១

រៀបចំដោយ៖ **សែ កុលវុឌ្ឍី** និង **Roger PHILLIPS**

| **កំណត់ហេតុអ្នកចូលរួម** |
|---|
| ចំពោះមុខ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម Jean-Marc LAVERGNE, ចៅក្រម យ៉ា សុខន, ចៅក្រម Claudia FENZ, ចៅក្រម យូ ឧត្តរា |
| ចៅក្រមបម្រុង៖ ចៅក្រម ធូ មណី, ចៅក្រម Martin KAROPKIN |
| ក្រឡាបញ្ជី៖ លោកស្រី សែ កុលវុឌ្ឍី, លោក Roger PHILLIPS, លោក ឯម ហ៊ាយ |
| ការិយាល័យសហព្រះរាជអាជ្ញា៖ កញ្ញា សុង ឆវ័ន្ត , លោក Dale LYSAK |
| ជនជាប់ចោទ៖ លោក នួន ជា (ពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ), លោក ខៀវ សំផន |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ នួន ជា៖ លោក សុន អារុណ, លោក លីវ សុវណ្ណា, លោក Victor KOPPE |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ ខៀវ សំផន៖ លោក គង់ សំអុន, លោកស្រី Anta GUISSÉ |
| ក្រុមមេធាវីប្រចាំការសម្រាប់ជនជាប់ចោទ ខៀវ សំផន៖ លោកស្រី ទូច វរល័ក្ស |
| មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖ លោកស្រី Marie GUIRAUD, លោក វ៉ែន ពៅ |
| សាក្សី/ដើមបណ្តឹង៖ លោកស្រី វង សារុន (2-TCW-986) |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក អ៊ុច អរុណ, លោកស្រី សួ សុទ្ធារី |

ផ្សេងៗ៖ លោក វ៉ាត សុម៉ៅ, កញ្ញា ស្រី ណាក់, លោកស្រី សំ មករា, លោក នូ មនោរ័ត្ន, លោក ហ៊ូ ជីសេង, កញ្ញា Joëlle TRAMPERT

| **ពេលវេលាទូទៅរបស់តុលាការ៖** | | |
|---|---|---|
| ថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១៥ | ចាប់ផ្ដើមម៉ោង៖ ០៩.១៣ | បញ្ចប់ម៉ោង៖ ១៥.៣០ |
| សម្រាកពេលព្រឹក | ចាប់ផ្ដើមម៉ោង៖ ០៩.៥៥ | បញ្ចប់ម៉ោង៖ ១០.១៣ |
| សម្រាកថ្ងៃត្រង់ | ចាប់ផ្ដើមម៉ោង៖ ១១.៥០ | បញ្ចប់ម៉ោង៖ ១៣.៣៣ |
| សម្រាកពេលរសៀល | ចាប់ផ្ដើមម៉ោង៖ ១៤.៤០ | បញ្ចប់ម៉ោង៖ ១៥.០២ |
| | ចំនួនម៉ោងសរុបរបស់តុលាការ៖ | ០៣ ម៉ោង និង ៥៣ នាទី |

**កិច្ចដំណើរការនីតិវិធីផ្សេងទៀត**

| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្ដើម | ម៉ោងបញ្ចប់ |
|---|---|---|---|
| ការប្រកាសបើកកិច្ចដំណើរការសវនាការ និងការប្រកាសពីវត្តមានរបស់ភាគី | អង្គជំនុំជម្រះ<br>ក្រឡាបញ្ជី | ០៩.១៤ | ០៩.១៥ |
| សំណើរបស់ នួន ជា ស្នើសុំចូលរួមកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ | មេធាវីការពារក្ដី នួន ជា | ០៩.១៥ | ០៩.១៨ |
| ការតាំងសំណួរទៅសាក្សី វង សារុន (2-TCW-986) | អង្គជំនុំជម្រះ<br><br>សហព្រះរាជអាជ្ញា<br>មេធាវីការពារក្ដី ខៀវ សំផន<br>មេធាវីការពារក្ដី នួន ជា | ០៩.១៨<br>១៣.៣៤<br>០៩.២៦<br>១៤.០០<br>១៤.១៤ | ០៩.២៦<br>១៣.៥៩<br>១១.៤៩<br>១៤.១៤<br>១៥.២៨ |
| មេធាវីការពារក្ដី នួន ជា បានស្នើសុំតាំងសំណួរទៅកាន់សាក្សី វង សារុន ក្រោយភាគីផ្សេងទៀត | អង្គជំនុំជម្រះ | ០៩.២៦ | ០៩.២៦ |
| សហព្រះរាជអាជ្ញាបានស្នើសុំដាក់ឯកសារមួយចំនួនដើម្បីសួរទៅសាក្សី វង សារុន (2-TCW-986) | សហព្រះរាជអាជ្ញា<br>អង្គជំនុំជម្រះ | ១១.២២<br>១១.២៣ | ១១.២៣<br>១១.២៩ |

**<u>សេចក្តីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖</u>**

**<u>ការប្រកាសបើកកិច្ចដំណើរការនីតិវិធីសវនាការ និងការប្រកាសពីវត្តមានរបស់ភាគី</u>**

ប្រធានអង្គជំនុំជម្រះប្រកាសបើកកិច្ចដំណើរការនីតិវិធីសវនាការ។ ក្រឡាបញ្ជីរាយការណ៍ថា គ្រប់ភាគីទាំងអស់មានវត្តមាន។ ដោយឡែកជនជាប់ចោទ នួន ជា មានវត្តមាននៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ។

**<u>សំណើរបស់ នួន ជា សុំចូលរួមកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ</u>**

អង្គជំនុំជម្រះសម្រេចអនុញ្ញាតតាមសំណើរបស់ជនជាប់ចោទ នួន ជា ដែលបានស្នើសុំលះបង់សិទ្ធិចូលរួមកិច្ចដំណើរការនីតិវិធីដោយផ្ទាល់ក្នុងសាលសវនាការ និងអនុញ្ញាតឱ្យគាត់តាមដានកិច្ចដំណើរការនីតិវិធីសវនាការពីបន្ទប់ឃុំខ្លួនស្ថិតនៅខាងក្រោមសាលសវនាការ។

**<u>ការតាំងសំណួរទៅសាក្សី វង សារុន (2-TCW-986)</u>**

អង្គជំនុំជម្រះបានតាំងសំណួរបឋមមួយចំនួន ព្រមទាំងប្រាប់អំពីសិទ្ធិ និងករណីយកិច្ចដល់សាក្សី។ បន្ទាប់មក សហព្រះរាជអាជ្ញា មេធាវីការពារក្តី ខៀវ សំផន និង មេធាវីការពារក្តី នួន ជា បានតាំងសំណួរទៅសាក្សី វង សារុន (2-TCW-986)។ មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានផ្តល់ពេលវេលារបស់ខ្លួនឱ្យទៅសហព្រះរាជអាជ្ញាក្នុងការតាំងសំណួរទៅសាក្សី។

**<u>មេធាវីការពារក្តី នួន ជា ស្នើសុំតាំងសំណួរទៅសាក្សី វង សារុន (2-TCW-986) បន្ទាប់ពីភាគីផ្សេងទៀត</u>**

មេធាវីការពារក្តី នួន ជា បានស្នើសុំតាំងសំណួរទៅសាក្សី វង សារុន នៅពេលរសៀល គឺក្រោយភាគីផ្សេងទៀត ដោយសារតែ លោក Victor Koppe អវត្តមាននៅពេលព្រឹកនៃសវនាការ។ មេធាវីការពារក្តី ខៀវ សំផន បានយល់ព្រមក្នុងការតាំងសំណួរទៅសាក្សីមុនមេធាវីការពារក្តី នួន ជា ហើយអង្គជំនុំជម្រះសម្រេចអនុញ្ញាតតាមសំណើសុំរបស់មេធាវីការពារក្តី នួន ជា។

**<u>សហព្រះរាជអាជ្ញាស្នើសុំដាក់ឯកសារមួយចំនួនក្នុងការតាំងសំណួរទៅសាក្សី វង សារុន (2-TCW-986)</u>**

សហព្រះរាជអាជ្ញា បានស្នើសុំយោងទៅលើឯកសារមួយដែលទាក់ទងនឹងកំណត់ហេតុនៃការសួរចម្លើយសាក្សី វង សារុន (2-TCW-986) នៅមន្ទីរសន្តិសុខក្រាំងតាចាន់។ អង្គជំនុំជម្រះបានសួរបញ្ជាក់ទៅសហព្រះរាជអាជ្ញាពីគោលបំណងនៃការប្រើប្រាស់ឯកសារនោះក្នុងការសួរទៅសាក្សី ដោយអង្គជំនុំជម្រះយល់ឃើញថាកំណត់ហេតុនោះអាចជាភស្តុតាងដែលទទួលបានពីការធ្វើទារុណកម្ម។ សហព្រះរាជអាជ្ញាបានលើកឡើងថាការប្រើប្រាស់ឯកសារនោះ ក្នុងគោលបំណងដើម្បីរំលឹកការចងចាំទៅសាក្សី បន្ទាប់មកអង្គជំនុំជម្រះបានអនុញ្ញាតតាមសំណើសុំនេះ។

**កំណត់ហេតុនៃកិច្ចដំណើរការនីតិវិធីតាមវិធាន ៨៧ (៣) វិធាននៃភស្តុតាង**

## Reclassified

| TC No | OCIJ No | ERN (KH, ENG, FR) | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|
| E3/4164 | | 00079337-00079338; 00973147-00973154; 00937104-00937106 | Prisoner List of a Re-education Office of Tram Kak District | P | 00079337 00079338 | 00973147 | 00937104 |
| E3/5860 | D157.13 | 00270815-00270854; 01064165-01064197; 00971272-00971316 | Biography of Thach Soeun from Kampuchea Krom | P | 00270827-00270829 | 01064174-01064176 | 00971285-00971288 |

## Other documents (No Change)

| TC No | OCIJ No | ERN (KH, ENG, FR) | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|
| E3/5827 | D157.7 | 00270855-00270897; 00866424-00866463; 00872799-00872835 | [Partial. T] Victim's background | P | 00270874 | 00866434 | 00872809 |
| E319/20.2 | | 01082099-01082101; 01072285-01072286; 01083305-01083307 | [Redacted] Written record of investigation action | SC | | | |

**ដីកា/សេចក្តីសម្រេចផ្ទាល់មាត់៖**

- អនុញ្ញាតឱ្យជនជាប់ចោទ នួន ជា បន្តតាមដានកិច្ចដំណើរនីតិវិធីសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ ហើយបង្គាប់ឱ្យផ្នែកសោតទស្សន៏ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា ដើម្បីបន្តសវនាការពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ។ (០៩.១៧)
- បង្គាប់អោយអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា និង ខៀវ សំផន ទៅកាន់មន្ទីរឃុំឃាំងវិញ នឹងបង្គាប់អោយនាំខ្លួនពួកគាត់ត្រឡប់មកកាន់សាលសវនាការវិញអោយបានមុនម៉ោង

| |
|---|
| ៩.00 ព្រឹក នៅថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១៥។ (១៥.២៩) |

| |
|---|
| **<u>កាលវេលាសវនាការបន្ត</u>** |
| សវនាការនឹងបន្តទៅថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១៥ ចាប់ផ្ដើមពីម៉ោង ០៩.00 ព្រឹក។ |

ភ្នំពេញ ថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១៥

ក្រឡាបញ្ជី

**សែ កុលវឌ្ឍី**

ក្រឡាបញ្ជី

**Roger PHILLIPS**